## លទ្ធផលរំពឹងទុករបស់កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុល

- បង្កើនកិច្ចសហការនៅកន្លែងធ្វើការ រវាងអ្នកគ្រប់គ្រងរោងចក្រ និង តំណាងសហជីព ដែលនេះអាចសំរេចទៅបានដោយសារសិក្ខាកាមមានឥរិយាបថកាន់តែវិជ្ជមាន ដើម្បីផ្តួចផ្តើមគំនិតបន្តកែលំអរោងចក្ររបស់ពួកគេ ។
- វិធីសាស្ត្រកាន់តែមានលក្ខណៈស្ថាបនា និង ជាប្រព័ន្ធ ដើម្បីគ្រប់គ្រង និង កែលំអរោងចក្រប្រកបដោយនិរន្តរភាព ។
- បង្កើនគុណភាព និង ផលិតភាព សំរាប់រោងចក្រនីមួយៗដែលចូលរួម ។
- កាត់បន្ថយវិវាទការងារ និង ការរំខានចំពោះផលិតភាពការងារ ។
- បង្កើនការចែករំលែកគំរូនៃ "ការអនុវត្តន៍ល្អៗបំផុត" នៅក្នុងចំណោមរោងចក្រដែលចូលរួម ។

## ភាពជោគជ័យរបស់កម្មវិធី



"កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលរបស់អង្គការពលកម្មអន្តរជាតិ បាននាំមកនូវការផ្លាស់ប្តូរវិជ្ជមានជាច្រើននៅក្នុងរោងចក្ររបស់យើងដូចជា កន្លែងធ្វើការកាន់តែមានអនាម័យល្អ សុវត្ថិភាពនិងសុខភាពការងារកាន់តែល្អប្រសើរ កាត់បន្ថយអវត្តមាន និង ជំរុញអោយគុណភាពនិងផលិតភាពកើនឡើង ។ យើងគាំទ្រដល់គំនិតផ្តួចផ្តើមនៃកម្មវិធីបណ្តុះបណ្តាល និងលើកទឹកចិត្តអោយកម្មកររបស់យើងចូលរួម ដូច្នេះពួកគេទទួលបានចំណេះដឹងនិងជំនាញបន្ថែមទៀត ។ នេះជាប្រយោជន៍ល្អសំរាប់អាជីវកម្មរបស់យើងនៅក្នុងរយៈពេលវែង និង ជួយបង្កើនផលិតភាពរបស់យើងផងដែរ ។"

លោក *Alex Chan* ប្រធានរោងចក្រខេមវែល



"កិច្ចសហប្រតិបត្តិការក្នុងចំណោមសហជីពទាំងបី មានលក្ខណៈល្អប្រសើរជាងមុន ខាងផ្នែកដោះស្រាយបញ្ហា ។ មានការកែលំអជាច្រើន ព្រោះកន្លងមកយើងធ្លាប់តែដោះស្រាយបញ្ហាដោយសហជីពនីមួយៗរៀងៗខ្លួន ហើយឥលូវនេះយើងសហការគ្នាដើម្បីដោះស្រាយបញ្ហារបស់កម្មករ ។ កិច្ចសហការនៅកន្លែងធ្វើការរវាងអ្នកគ្រប់គ្រង និង កម្មករនិយោជិតក៏មានការកែលំអផងដែរ ។ បញ្ហាដែលយើងមាន យើងអាចដោះស្រាយបានភ្លាមៗ និង/ឬ បានទាន់ពេលវេលា ។"

លោក *សំ សោភា* ប្រធានសហជីព រោងចក្រអឹមអេសអាយ


**អង្គការពលកម្មអន្តរជាតិ**
***រោងចក្រកាន់តែប្រសើរនៅកម្ពុជា***
ផ្ទះលេខ ៩ ផ្លូវលេខ ៣២២
បឹងកេងកង ១ ចំការមន
ភ្នំពេញ ប្រទេសកម្ពុជា

ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ: (៨៥៥-២៣) ២១២ ៨៤៧ / ២២០ ៣៦២
ទូរសារ: (៨៥៥-២៣) ២១២ ៩០៣
អ៊ីម៉ែល: betterfactories@ilo.org
វ៉ិបសាយ: www.betterfactories.org/ilo


# រោងចក្រកាន់តែប្រសើរនៅកម្ពុជា

# កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុល



អង្គការពលកម្មអន្តរជាតិ



## ទិដ្ឋភាពទូទៅ

ឧស្សាហកម្មកាត់ដេរ ដែលជួលកម្មករនិយោជិតចំនួនជិត ៣៥០ ០០០ នាក់អោយធ្វើការ គឺជាវិស័យការងារធំជាងគេតែមួយគត់នៅក្នុងប្រទេសកម្ពុជា និង ជាវិស័យដែលទទួលចំណូលពីការនាំចេញនាំមុខគេសំរាប់ប្រទេសនេះ ។ ជាមួយនឹងកំណើនការចាប់អារម្មណ៍ជាសកលចំពោះល័ក្ខខ័ណ្ឌការងាររួមជាមួយនឹងបរិយាកាសប្រកួតប្រជែងអន្តរជាតិ មានតំរូវការយ៉ាងខ្លាំងក្លាក្នុងការផ្តល់នូវការបណ្តុះបណ្តាលប្រកបដោយគុណភាព ដែលផ្តល់ឱកាសអោយសិក្ខាកាមកំណត់ពីបញ្ហានានាដែលជាក្តីកង្វល់ និង ស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធភាពដោយខ្លួនឯង ។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបំពេញនូវសេចក្តីត្រូវការផ្នែកបណ្តុះបណ្តាលទាំងនេះ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ និង អង្គការបណ្តុះបណ្តាលជាដៃគូរបស់ខ្លួន VBNK ផ្តល់នូវកម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលមួយ ដែលមានគោលបំណងរៀបចំវិស័យឧស្សាហកម្មនេះ អោយត្រៀមដោះស្រាយបញ្ហាប្រឈមដែលនឹងមកដល់ ។

នៅក្នុងរយៈពេល ៤ ឆ្នាំកន្លងទៅនេះ កម្មវិធីនេះត្រូវបានអនុវត្តនៅក្នុងរោងចក្រចំនួន ៤៧ និង បានបង្កើតនូវលទ្ធផលល្អប្រសើរគួរអោយកត់សំគាល់ ខាងការកែលំអទំនាក់ទំនងនៅកន្លែងធ្វើការ ការបង្កើនគុណភាព និង ផលិតភាព ។

## រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល

កម្មវិធីតាមម៉ូឌុលនេះ ប្រើប្រាស់វិធីសាស្ត្រទ្វេរភាគី ដោយអ្នកគ្រប់គ្រងរោងចក្រ និង តំណាងកម្មករនិយោជិត សិក្សារួមគ្នា ។ គ្រប់វគ្គបណ្តុះបណ្តាលទាំងអស់ត្រូវបានរៀបចំឡើង ដោយមានការបកប្រែប្រដេញជាភាសាខ្មែរ ចិន និង អង់គ្លេស ហើយឯកសាររបស់សិក្ខាកាមក៏ត្រូវបានរៀបចំឡើងជាបីភាសាផងដែរ ។ ការបណ្តុះបណ្តាលនេះ រួមបញ្ចូលការសិក្សានៅក្នុងថ្នាក់រៀន ជាមួយនឹងសកម្មភាពតាមដាននៅក៏រិតរោងចក្រ ។

### សិក្ខាសាលានៅក្នុងថ្នាក់រៀន ( ថ្ងៃទី ១ និង ទី ២)

ម៉ូឌុលនីមួយៗ (លើកលែងតែម៉ូឌុលដំបូង និង ម៉ូឌុលចុងក្រោយ ដែលការបណ្តុះបណ្តាលមានតែមួយថ្ងៃ) មានការបណ្តុះបណ្តាលនៅក្នុងថ្នាក់រៀនចំនួនពីរថ្ងៃកន្លះ រួមជាមួយនឹងកិច្ចប្រជុំតាមដាន និង ការកែលំអនៅក្នុងរោងចក្រ ។

### ការចុះពិនិត្យការកែលំអនៅក្នុងរោងចក្រ

ក្នុងរយៈពេលពីរឬបីថ្ងៃបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលនៅក្នុងថ្នាក់រៀនរួចហើយ ក្រុមបុគ្គលិកអង្គការពលកម្មអន្តរជាតិ (និង/ឬ អ្នកសំរបសំរួលដែលពាក់ព័ន្ធ) ចុះទៅកាន់រោងចក្រនីមួយៗ ដើម្បីជួបជាមួយនឹងតំណាងរោងចក្រ ពិភាក្សាពីការយកចំណេះដឹងដែលទទួលបានពីថ្នាក់រៀនមកអនុវត្តនៅក្នុងរោងចក្រ និង បញ្ចប់ផែនការកែលំអរោងចក្រ (FIP) ដោយឯកភាពគ្នាលើកាលបរិច្ឆេទបញ្ចប់ និង អ្នកដែលទទួលខុសត្រូវលើការកែលំអនីមួយៗ ។

### ការបណ្តុះបណ្តាលថ្ងៃទី ៣

ការបណ្តុះបណ្តាលថ្ងៃទី ៣ ដែលមានរយៈពេលកន្លះថ្ងៃ ធ្វើឡើងបន្ទាប់ពីការចុះតាមដានលើកទីពីររបស់អង្គការពលកម្មអន្តរជាតិ ។ វគ្គថ្ងៃទី ៣ នេះ រៀបចំឡើងដើម្បីផ្តល់អោយរោងចក្រនីមួយៗ នូវឱកាសបង្ហាញផែនការកែលំអរោងចក្ររបស់ខ្លួន ទៅកាន់អ្នកដែលមកពីរោងចក្រដទៃទៀត ។ បទបង្ហាញមានរយៈពេលពី ១០ ទៅ ១៥ នាទី ហើយរោងចក្រត្រូវបានលើកទឹកចិត្តអោយប្រើបទបង្ហាញតាមបែប PowerPoint (តែមិនតំរូវឡើយ) ដើម្បីបង្ហាញពីការកែលំអ និង/ឬ គំរូនៃការអនុវត្តន៏ល្អៗបំផុតរបស់ពួកគេ និង ប្រើប្រាស់រូបថត "មុន និង ក្រោយ" ដើម្បីបង្ហាញពីការកែលំអដែលសំរេចបាន ។

## វិធីសាស្ត្រ

វិធីសាស្ត្របណ្តុះបណ្តាល គឺផ្តោតលើមនុស្សពេញវ័យ និង មានលក្ខណៈចូលរួម ដោយផ្តល់ឱកាសអោយសិក្ខាកាមចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការទទួលបានព័ត៌មានថ្មីៗ។ លំហាត់ទាំងនេះ លើកកំពស់ភាពច្នៃប្រឌិត និង ភាពបត់បែន ។ ការទទួលបានចំណេះដឹងថ្មីៗកើតមានឡើងដោយសារតែសិក្ខាកាមរំភើបរីករាយ និង មានការលើកទឹកចិត្តតាមរយៈលំហាត់អនុវត្តន៏ ដែលមានភាពជាក់លាក់ទៅនឹងតំរូវការរៀនសូត្ររបស់ពួកគេ ។ សិក្ខាកាមអាចផ្សារភ្ជាប់បទពិសោធន៏ផ្ទាល់ខ្លួនរបស់ពួកគេទៅនឹងបញ្ហាផ្ទាល់ខ្លួន និងបញ្ហាសង្គម ដែលអាចមានប្រយោជន៏ដល់ការរៀនសូត្រ ។ ដើម្បីទទួលបានជោគជ័យ វិធីសាស្ត្រនេះត្រូវការអោយមានបរិស្ថានមួយដែលមានការគោរពគ្នាទៅវិញទៅមក ដែលអ្នកសិក្សាមានអារម្មណ៏ងាយស្រួលក្នុងការចែករំលែកទស្សនៈនិងការយល់ឃើញផ្សេងៗគ្នា ដោយមិនប្រកាន់ប្រវត្តិ វប្បធម៌ សង្គម និង ការអប់រំ របស់ពួកគេ ។

## មាតិកា



កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុល ចែកចេញជា ៧ ម៉ូឌុលផ្សេងៗគ្នា ដែលជាធម្មតាត្រូវបានរៀបចំឡើងនៅក្នុងរយៈពេល ១២ ខែ ។ នៅចន្លោះពីម៉ូឌុលមួយទៅម៉ូឌុលមួយ រោងចក្រមានឱកាសអនុវត្តអ្វីដែលពួកគេបានរៀន តាមរយៈការប្រើប្រាស់ផែនការកែលំអរោងចក្រ (FIP) ដោយមានការគាំទ្រពីបុគ្គលិករបស់អង្គការពលកម្មអន្តរជាតិ និង របស់អង្គការដៃគូ។

ម៉ូឌុលទាំង ៧ រួមមានៈ

- បរិបទសកល (មួយថ្ងៃប៉ុណ្ណោះ)
- កិច្ចសហការនៅកន្លែងធ្វើការ
- គុណភាព
- សុវត្ថិភាព និង សុខភាពការងារ (OSH)
- ផលិតភាព
- ការគ្រប់គ្រងធនធានមនុស្ស និង ល័ក្ខខ័ណ្ឌការងារ
- ការកែលំអជាប្រចាំ (មួយថ្ងៃប៉ុណ្ណោះ)

*កំណត់សំគាល់: ប្រសិនបើមិនមានការបញ្ជាក់ទេ ម៉ូឌុលទាំងនេះរួមមានការបណ្តុះបណ្តាលនៅក្នុងថ្នាក់រៀនចំនួនពីរថ្ងៃកន្លះ ជាមួយនឹងការចុះតាមដាននៅក្នុងរោងចក្រ ។*





## អ្នកផ្តល់ការបណ្តុះបណ្តាល

កម្មវិធីនេះ នឹងត្រូវបានធ្វើឡើងរួមគ្នាជាមួយនឹងអង្គការបណ្តុះបណ្តាលនាំមុខគេនៅកម្ពុជា ដែលមានកេរ្តិ៍ឈ្មោះល្អខាងការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានគុណភាពល្អ គឺ អង្គការ VBNK ។

## ថ្លៃឈ្នួល

ថ្លៃឈ្នួលនៃការបណ្តុះបណ្តាល សំរាប់រោងចក្រដែលចូលរួមនីមួយៗគឺ ២៥០០ ដុល្លាសហរដ្ឋអាមេរិក ដែលត្រូវបង់ជាមុន ។ ថ្លៃឈ្នួលនេះគឺសំរាប់គ្រប់វគ្គបណ្តុះបណ្តាល ឯកសារ និង ការគាំទ្រក៏រិតរោងចក្រទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងកម្មវិធី ។ ថ្លៃឈ្នួលនេះគឺជាការចូលរួមចែករំលែកការចំណាយ ជាមួយនឹងគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ដើម្បីបំពេញការចំណាយដទៃទៀត តាមរយៈការគាំទ្រពីម្ចាស់ជំនួយ ទីភ្នាក់ងារអភិវឌ្ឍន៏បារាំង (AFD) ។

## ព័ត៌មានលំអិតបន្ថែម

សូមដាក់ពាក្យដើម្បីចូលរួមនៅក្នុងកម្មវិធីនេះ ដោយទាក់ទងមក កញ្ញា *លាង ចន្ធី* តាមរយៈអ៊ីម៉េល chanthy@ilo.org ឬ ទូរស័ព្ទលេខ (៨៥៥-២៣) ២១២ ៨៤៧ ភ្ជាប់បន្តទៅលេខ ២២៩ ។ សំរាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ សូមទាក់ទងមក លោក *ខន័រ ប៊យ* អនុប្រធានគំរោង នៃកម្មវិធីកែលំអរោងចក្ររបស់អង្គការពលកម្មអន្តរជាតិ តាមរយៈអ៊ីម៉េល boyle@ilo.org ឬ ទូរស័ព្ទលេខ (៨៥៥-២៣) ២១២ ៨៤៧ ភ្ជាប់បន្តទៅលេខ ១១៤ ។